**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ..៣៦៨...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## វិសោធនកម្មមាត្រា ៧ និង មាត្រា ២០

## នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥

## ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស / រកម / ០១៩៥/ ០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ ជស / រកម/០៦៩៦/ ០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្ត ព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្នងការគណនី នៃសហគ្រាសសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា តែមួយ.-**

មាត្រា ៧ និង មាត្រា ២០ នៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា៧ ថ្មី.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបំរើការងារយ៉ាង តិច ៥ ( ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុមិនលើសពី ៦៥ ( ហុកសិបប្រាំ) ឆ្នាំ និង មានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមិនដែលត្រូវផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិបីឆ្នាំ។ អាណត្តិនេះ អាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬអង្គភាពដែលខ្លួនតំណាងឱ្យ ។ តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមនិយោជិតរបស់ **ទ.ក.** ។ ចាប់ពីអាណត្តិបន្ទាប់ពីអាណត្តិនេះតទៅ ពុំមានបេក្ខជនណាម្នាក់ដែលមានជម្លោះផលប្រយោជន៍ដោយផ្ទាល់ជាមួយទូរគមនាគមន៍កម្ពុជា នឹងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឡើយ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវការពារផលប្រយោជន៍របស់ទូរគមនាគមន៍កម្ពុជា និង ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរក្សាការសម្ងាត់ជាអាជីព ដោយមិនត្រូវឱ្យលេចធ្លាយនូវពត៌មានសម្ងាត់របស់ទូរគមនាគមន៍កម្ពុជា ទៅឱ្យភាគីខាងក្រៅណាមួយឡើយ។ ប្រសិនបើបានរកឃើញថា មានកំហុសក្នុងការប្រព្រឹត្តផ្ទុយនឹងផលប្រយោជន៍របស់ទូរគមនាគមន៍កម្ពុជានោះ សមាជិកក្រុមប្រឹក្សាភិបាលរូបនោះ នឹងត្រូវដកចេញពីក្រុមប្រឹក្សាភិបាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យមើលបញ្ហា និងស្នើសុំទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីដកសមាជិកភាព ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវដាក់សំណើសុំសេចក្តីសម្រេចពីរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា២០ ថ្មី.-**

ចំពោះច្បាប់ថវិកាសំរាប់ឆ្នាំ ២០០៥ ទូរគមនាគមន៍កម្ពុជាត្រូវផ្តល់ចំណូលដុលចំនួន ៥១ % នៃសេវាទូរគមនាគមន៍អន្តរជាតិ និង ៥% នៃសេវាទូរគមនាគមន៍ក្នុងប្រទេស ចូលថវិកាជាតិ។ សំរាប់ឆ្នាំបន្តបន្ទាប់ យន្តការបែងចែកប្រាក់ចំណូលនឹងត្រូវកំណត់តាមការផ្តល់អនុសាសន៍របស់ជំនួយបច្ចេកទេស ដែលផ្តល់ថវិកាដោយធនាគារអភិវឌ្ឍន៍អាស៊ី។ អនុសាសន៍នៃការបែងចែកនេះ នឹងត្រូវពិភាក្សាដោយធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានដល់ការឯកភាពគ្នា លើទំរង់បែងចែកប្រាក់ចំណូលពីក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា ក៏ដូចជាប្រាក់ចំណូលពីវិស័យទូរគមនាគមន៍ទាំងមូល។ ជំនួយបច្ចេកទេសនេះនឹងត្រូវបានចាប់ផ្តើមអនុវត្តភ្លាម បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

**មាត្រា ពីរ.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា បី ✓
-ឯកសារ-កាលប្បវត្តិ